# អន្តរកាល ៖ ជំហានបន្ទាប់ ៖

## តើនឹងមានអ្វីកើតឡើងនៅពេលកូនខ្ញុំឈានដល់អាយុបីឆ្នាំ?



*សៀវភៅណែនាំអំពីការធ្វើអន្តរកាលពីសេវាអន្តរាគមន៍បឋមវ័យ ក្រោមមាត្រា Part C នៃច្បាប់អប់រំបុគ្គលដែលមានពិការភាព (IDEA)។*

មូលនិធិទ្រទ្រង់ដោយកម្មវិធីឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារក្មេងខ្ចីរបស់ក្រសួងកុមារ យុវជន និងគ្រួសារ។

Washington State Department of
CHILDREN, YOUTH & FAMILIES

## តើអន្តរកាលជាអ្វី?

នៅពេលកូនរបស់លោកអ្នកឈានដល់អាយុបីឆ្នាំ, នោះសេវាអន្តរាគមន៍បឋមវ័យ (Early Intervention Services) នឹងត្រូវចប់ ហើយសេវា និងកម្មវិធីឧបត្ថម្ភថ្មីអាចនឹងមានបម្រើការជូនលោកអ្នកជាបន្តទៅទៀត។ ដំណើរការផ្លាស់ប្តូរនេះគឺជាអន្តរកាលមួយក្នុងចំណោមអន្តរកាលជាច្រើន ដែលអាចកើតមានដល់កូន និងគ្រួសាររបស់លោកអ្នក នៅក្នុងដំណាក់កាលនីមួយៗនៃជីវិតរបស់លោកអ្នក។

នៅក្នុងរយៈពេលប្រាំមួយទៅប្រាំបួនខែមុនថ្ងៃខួបកំណើតទីបីរបសកូនលោកអ្នក, នោះលោកអ្នកនឹងចាប់ផ្តើមធ្វើការជាមួយបុគ្គលិកសម្របសម្រួលធនធានគ្រួសារ (Family Resources Coordinator, FRC) របស់លោកអ្នក និងក្រុមការងាររបសលោកអ្នក ដើម្បីរៀបចំផែនការសម្រាប់អន្តរកាលឆ្ពោះទៅរកជម្រើសកម្មវិធីអប់រំនៅតាមសាលា ឬជម្រើសសេវាកម្មដទៃៗទៀត។ គ្រួសារ និងអ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនលោកអ្នកនឹងធ្វើការឆ្លងកាត់ដំណាក់កាលនេះជាមួយលោកអ្នក ដើម្បីឈានទៅបង្កើតការប្រជុំអន្តរកាលណាមួយឡើង។

## តើគោលបំណងនៃការប្រជុំអន្តរកាលមានអ្វីខ្លះ?

នៅក្នុងអំឡុងនៃការប្រជុំអន្តរកាល, ផែនការជាលាយលក្ខណ៍អក្សរមួយនឹងត្រូវបង្កើតឡើងដោយលោកអ្នក និងក្រុមការងារសេវាអន្តរាគមន៍បឋមវ័យរបស់លោកអ្នក ដើម្បីណែនាំលោកអ្នកក្នុងការធ្វើដំណើរឆ្លងកាត់ដំណាក់កាលនៃអន្តរកាលនេះ។

ច្បាប់អប់រំបុគ្គលដែលមានពិការភាព (Individuals with Disabilities Education Act, IDEA) តម្រូវឲ្យមានការរៀបចំផែនការជាលាយលក្ខណ៍អក្សរ សម្រាប់ការធ្វើអន្តរកាលនៅថ្ងៃខួបកំណើតទីបីរបស់កូនលោកអ្នក។

## តើយើងចាប់ផ្តើមរៀបចំផែនការសម្រាប់អន្តរកាលនៅពេលណា?

**ប្រាំមួយទៅប្រាំបួនខែមុនថ្ងៃខួបកំណើតទីបីរបស់កូនលោកអ្នក ៖**

ការរៀបចំផែនការអន្តរកាលនឹងចាប់ផ្តើម។ បុគ្គលិករបស់លោកអ្នកនឹងជួយសម្របសម្រួលការទាក់ទងរវាងលោកអ្នក និងមណ្ឌលសិក្សាធិការរបលលោកអ្នក ឬកម្មវិធីដទៃៗទៀតក្នុងសហគមន៍ ដើម្បីចាប់ផ្តើមរៀបចំផែនការសម្រាប់អន្តរកាលរបស់កូនលោកអ្នក នៅពេលវាឈានដល់អាយុបីឆ្នាំ។

**យ៉ាងតិចណាស់បីខែមុនថ្ងៃខួបកំណើតទីបីរបស់កូនលោកអ្នក, ការប្រជុំរៀបចំផែនការអន្តរកាលនឹងត្រូវធ្វើឡើង ៖**

លោកអ្នកនឹងជួបជាមួយអ្នកតំណាងមណ្ឌលសិក្សាធិការ ដែលជាផ្នែកមួយនៃការប្រជុំនេះ។ ពួកគេនឹងពន្យល់ប្រាប់លោកអ្នកឲ្យបានជ្រាបអំពីអ្វីដែលនឹងកើតឡើង ដើម្បីកំណត់មើលថាតើកូនរបស់លោកអ្នកមានគុណសម្បត្តិទទួលសេវាអប់រំពិសេសនៅក្នុងកម្មវិធីអប់រំមុនវ័យចូលរៀនឬយ៉ាងណា។

ប្រសិនបើកូនរបស់លោកអ្នកមានគុណសម្បត្តិទទួលសេវាអប់រំពិសេសនៅក្នុងកម្មវិធីអប់រំមុនវ័យចូលរៀន, ដូចដែលបានកំណត់ឃើញដោយមណ្ឌលសិក្សាធិការ, នោះសេវាទាំងនោះនឹងត្រូវបានគេផ្តល់ជូនតាមរយៈកម្មវិធីអប់រំឯកត្តជន (Individualized Education Program, IEP).

នឹងគ្មានការកំណត់ពេលប្រជុំជាមួយអ្នកតំណាងមណ្ឌលសិក្សាធិការនោះទេ ប្រសិនបើអ្នកគ្មានបំណងទទួលគុណសម្បត្តិទទួលសេវាអប់រំពិសេសនៅក្នុងកម្មវិធីអប់រំមុនវ័យចូលរៀនទេនោះ។

## តើផែនការអន្តរកាលជាអ្វី?

ផែនការអន្តរកាលគឺជាផែនការមួយ ពន្យល់អំពីរបៀប ដែលលោកអ្នក, បុគ្គលិក FRC របស់លោកអ្នក និងក្រុមការងារសេវាអន្តរាគមន៍បឋមវ័យរបស់លោកអ្នកនឹងជួយ ក្នុងខណៈពេលដែលកូន និងគ្រួសាររបស់លោកអ្នកចេញផុតពី សេវាអន្តរាគមន៍បឋមវ័យ នៅពេលកូនរបស់លោកអ្នកឈានដល់អាយុបីឆ្នាំ។ ផែនការនេះពណ៌នាអំពីប្រភេទនៃសេវាឧបត្ថម្ភនានា ដែលកូនរបស់លោកអ្នកត្រូវការ ក្នុងខណៈពេលដែលវាចូលរៀនក្នុងកម្មវិធីអប់រំពិសេសនៃមណ្ឌលសិក្សាធិការមូលដ្ឋានរបស់លោកអ្នក, ឬក្នុងខណៈពេលដែលវាចូលរៀនក្នុងកម្មវិធីអប់រំពិសេសនៃមណ្ឌលសិក្សាធិការមូលដ្ឋានរបស់លោកអ្នក ឬក្នុងកម្មវិធីដទៃៗទៀតក្នុងសហគមនរបស់លោកអ្នក, ឬក្នុងខណៈពេលដែលកូនរបស់លោកអ្នកចាកចេញពីសេវាឧបត្ថម្ភ និងសេវាជំនួយទាំងនេះ ដោយព្រោះវាលែងមានលក្ខណសម្បត្តិទទួលសេវាជំនួយ និងសេវា ឧបត្ថម្ភពាក់ព័ន្ធការអភិវឌ្ឍន៍កាយសម្បទាយឺតយ៉ាវ ឬពិការភាពរបស់វាជាបន្តទៅទៀត។

## តើនឹងមានអ្វីកើតឡើងជាបន្តទៀតសម្រាប់កូនរបស់ខ្ញុំ?

**ឧការបង្កើតផែនការអន្តរកាលរបស់កូនខ្ញុំ ៖**

លោកអ្នក និងក្រុមការងារសេវាអន្តរាគមន៍បឋមវ័យរបស់លោកអ្នកនឹងធ្វើការជាមួយគ្នា ដើម្បីបង្កើតផែនការនេះ។ ក្រុមការងាររួមមានលោកអ្នក, បុគ្គលិក FRC របស់លោកអ្នក, បណ្តាមនុស្សដែលឥឡូវនេះធ្វើការជាមួយកូនរបស់លោកអ្នក, និងបណ្តាបុគ្គលដែលលោកអ្នកចង់ឲ្យចូលរួម ព្រមទាំងបណ្តាមនុស្ស ដែលអាចនឹងពាក់ព័ន្ធដល់អនាគតរបស់កូនលោកអ្នក។ ក្រុមការងារនេះនឹងពិនិត្យមើលការរីកចម្រើន និងសេចក្តីត្រូវការនានារបស់កូនលោកអ្នក។ បុគ្គលិក FRC នឹងសម្របសម្រួលការបង្កើតផែនការអន្តរកាលនេះ។

### តើអាចនឹងមានសេវាអ្វីខ្លះមានបម្រើការសម្រាប់កូនរបស់ខ្ញុំ នៅក្រោយអន្តរកាលអាយុបីឆ្នាំ?

នោះគឺវាអាស្រ័យលើថាតើកូនរបស់លោកអ្នកត្រូវការសេវាអប់រំពិសេសសម្រាប់កុមារភាពបឋមវ័យឬអត់។ មណ្ឌលសិក្សាធិការរបស់លោកអ្នកនឹងកំណត់មើល ថាតើកូនរបស់លោកអ្នកមានគុណសម្បត្តិទទួលសេវាអប់រំពិសេសសម្រាប់កុមារភាពបឋមវ័យឬទេ។ ប្រសិនបើកូនរបស់លោកអ្នក, ដូចជាកម្មវិធីអប់រំតាមសហគមន៍, កម្មវិធី Head Start, កម្មវិធី Early Childhood Education and Assistance Program (កម្មវិធីអប់រំ និងជំនួយសម្រាប់កុមារភាពបឋមវ័យ, ECEAP), ឬកម្មវិធីអប់រំតាមផ្ទះ, ឬកម្មវិធីអប់រំតាមសាលាជាដើម។ កម្មវិធីអប់រំពិសេស ហើយនិងសេវាពាក់ព័ន្ធផ្សេងៗទៀតនឹងត្រូវបានផ្តល់ជូនតាមរយៈ កម្មវិធីអប់រំឯកត្តជន (Individualized Education Program, IEP). បុគ្គលិក FRC នឹងសម្របសម្រួលការប្រជុំផែនការអន្តរកាល។ មណ្ឌលសិក្សាធិការនឹងរៀបចំការប្រជុំមួយដើម្បីបង្កើតផែនការ IEP របស់កូនលោកអ្នក។

លោកអ្នកអាចស្នើសុំឲ្យមានការអញ្ជើញបុគ្គលិក FRC របស់អ្នកឲ្យចូលរួមនៅក្នុងការប្រជុំ IEP ដែរ។ អ្នកអាចនាំមិត្តភក្តិ, សមាជិកគ្រួសារ, ឬសមាជិកសហគមន៍ណាម្នាក់ដែលលោកអ្នកពេញចិត្តមកជាមួយលោកអ្នក ដើម្បីជួយគាំពារលោកអ្នក។ ប្រសិនបើលោកអ្នកមាននាយកគ្រប់គ្រងសំណុំរឿង នាយកដ្ឋានអភិវឌ្ឍន៍ពិការភាព (Division of Developmental Disabilities, DDD) ឬអ្នកសម្របសម្រួលសំណុំរឿងកុមារដែលមានតម្រូវការថែទាំសុខភាពពិសេស (Children with Special Health Care Needs, CSHCN) នោះលោកអ្នកប្រហែលជាគួរទៅជួបពួកគេផងដែរ។ ការប្រជុំ IEP ត្រូវតែធ្វើឡើងឲ្យបានមុនថ្ងៃខួបកំណើតទីបីរបស់កូនលោកអ្នក។ នៅក្រោយពេលផែនការ IEP ដំបូងរបស់លោកអ្នកបានចងក្រងចប់ស្រេចបាច់ហើយ, នោះការប្រជុំតែ អាចនឹងប្រព្រឹត្តទៅនៅពេលណាក៏បាន ទៅតាមកាលៈទេសៈ ដែលលោកអ្នក ឬបុគ្គលិកសិក្សា របស់លោកអ្នកយល់ថាចាំបាច់ដើម្បីពិភាក្សាអំពីកម្មវិធីអប់រំរបស់កូនលោកអ្នក។

### តើនឹងមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំពុំមានគុណសម្បត្តិទទួលសេវាអប់រំពិសេសសម្រាប់កុមារភាពបឋមវ័យ?

ប្រសិនបើកូនរបស់លោកអ្នកពុំមានលក្ខណសម្បត្តិទទួលសេវាអប់រំពិសេសសម្រាប់កុមារភាពបឋមវ័យ នោះបុគ្គលិក FRC នឹងធ្វើការជាមួយលោកអ្នក ដើម្បីរុករកជម្រើសជាយថាហេតុផ្សេងៗទៀត ដែលអាចមានបម្រើការដល់កូនរបស់លោកអ្នក, ដូចជា កម្មវិធី Head Start, កម្មវិធី ECEAP, ឬកម្មវិធីអប់រំតាមសហគមន៍ដទៃៗទៀត។

## តើតួនាទីរបស់យើងនៅក្នុងដំណើរការអន្តរកាលមានអ្វីខ្លះ?

**តម្រុយស្តីពីរបៀប ដែលលោកអ្នកអាចជួយកូន និងគ្រួសាររបស់លោកអ្នក ដើម្បីធ្វើអន្តរកាលឲ្យបានរលូន ៖**

- ចូលរួមក្នុងការប្រជុំនានា ដើម្បីនិយាយអំពីអ្វីដែលលោកអ្នកចង់បាន សម្រាប់កូនរបស់លោកអ្នក។
- កត់កំណត់ហេតុនៃការប្រជុំនានា។
- រុករកធនធាន និងសេវានានា។
- រក្សាកំណត់ហេតុអំពីសកម្មភាព និងចំណូលចិត្តនានារបស់លោកអ្នកទុកក្នុងកូនសៀវភៅណាមួយ។ រក្សាទុកសំបុត្រកំណើត, សំបុត្រចាក់ថ្នាំបង្ការរោគ, សំបុត្រវេជ្ជសាស្ត្រ, រូបថត, របាយការណ៍វាយតម្លៃដើមហេតុ, របាយការណ៍វាយតម្លៃលទ្ធផល, និង របាយការណ៍ IFSP អតីតនានា។ រូបថតរបស់កូនលោកអ្នកជួយបង្ហាញអំពីអង្គហេតុ និងពត៌មានផ្ទាល់ខ្លួនរបស់កូនលោកអ្នក
- តើអ្វីដែលអាចជាជំនួយ ដើម្បីគាំពារកូនរបស់លោកអ្នក? លោកអ្នកជាមនុស្សដែលស្គាល់កូនរបស់លោកអ្នកច្បាស់លាស់ជាងគេ។ លោកអ្នកត្រូវដឹងអំពីអ្វីដែលគួររំពឹងពីកូនរបស់លោកអ្នកហើយត្រូវធ្វើការជាមួយមណ្ឌលសិក្សាធិការ និងក្រុមការងារ IEP ដើម្បីស្វែងរកសេវាទាំងនោះសម្រាប់កូនលោកអ្នក។

## តើជំហាននានារបស់ខ្ញុំបន្ទាប់ពីអន្តរកាលមានអ្វីខ្លះ?

សួរថាតើគេមានក្រុមទ្រទ្រង់គ្រួសារ, សមាគមមាតាបិតាគ្រូសិស្ស (Parent Teacher Student Association, PTSA) ប្រចាំមូលដ្ឋាន, ឬក្រុមប្រឹក្សាផ្តល់ឱវាទមាតាបិតាស្តីពីកម្មវិធីអប់រំពិសេស (Special Education Parent Advisory Council, SEPAC) នៅក្នុងមណ្ឌលសិក្សាធិការរបស់លោកអ្នកឬទេ។ ចូរសួរថាតើមណ្ឌលសិក្សាធិការនេះមានបុគ្គលិកសេវាបម្រើគ្រួសារ ឬបុគ្គលិកការងារសង្គមកិច្ចណាម្នាក់ ដែលអាចជួយលោកអ្នក បើសិនជាលោកអ្នកមានការបារម្ភផ្សេងៗឬទេ។ ចូរចងចាំថា លោកអ្នក, ដែលជាឪពុកម្តាយ, អាចនឹងទទួលបានផលប្រយោជន៍ពីការទ្រទ្រង់នេះសម្រាប់ខ្លួនលោកអ្នកផ្ទាល់, ក៏ដូចជាសម្រាប់កូនរបស់លោកអ្នកដែរ, ខណៈពេលដែលគ្រួសាររបស់លោកអ្នកធ្វើដំណើរឆ្លងកាត់ដំណាក់កាលនៃអន្តរកាលនេះ។

## តើយើងត្រូវការដឹងអំពីពត៌មានផ្សេងៗអ្វីខ្លះទៀត?

ប្រសិនបើសព្វថ្ងៃនេះ កូនរបស់លោកអ្នកមានលក្ខណសម្បត្តិទទួលសេវាពីនាយកដ្ឋាន DDD, នោះការមានលក្ខណសម្បត្តិទទួលសេវាទាំងនេះត្រូវតែបានកំណត់ឡើងវិញ នៅមុនពេលកូនរបស់លោកអ្នកឈានដល់អាយុបួនឆ្នាំ។ វាជាការសំខាន់ណាស់ ដែលលោកអ្នកត្រូវតែចែករំលែកពត៌មានស្តីអំពីការវាយតម្លៃសេវាអន្តរាគមន៍បឋមវ័យ និងពត៌មានអន្តរកាលហើយនិងពត៌មានស្តីអំពីការវាយតម្លៃលទ្ធផល/ការវាយតម្លៃដើមហេតុរបស់សាលារៀនក្នុងដំណាក់កាលអន្តរកាលនេះ ជាមួយនាយកដ្ឋាន DDD. **ការយល់ព្រមរបស់លោកអ្នកក្នុងការបើកបញ្ចេញពត៌មាននេះទៅឲ្យនាយកដ្ឋាន DDD អាចស្នើសុំពីមណ្ឌលសិក្សាធិការនៅក្នុងអំឡុងពេលប្រជុំរៀបចំផែនការអន្តរកាលនេះ។** ប្រសិនបើពត៌មានដែលគេត្រូវការ ដើម្បីកំណត់មើលលក្ខណសម្បត្តិ បន្តទទួលជំនួយរបស់កូនលោកអ្នក មិនត្រូវបានគេទទួលបានទេ នោះកូនរបស់លោកអ្នកនឹងត្រូវគេទម្លាក់ចេញពីសេវា DDD នៅពេលកូននោះឈានដល់អាយុបួនឆ្នាំ។

# តើខ្ញុំអាចទៅសុំជំនួយ ឬពត៌មានបន្ថែមនៅទីណា?



កម្មវិធីនៃក្រសួងកុមារ យុវជន និងគ្រួសារ (Department of Children, Youth, and Families) ការគាំទ្រពេលដំបូងសម្រាប់ទារក និងក្មេងចេះដើរ (ESIT) ដឹកនាំប្រព័ន្ធសេវាអន្តរាគមន៍បឋមវ័យក្រោមច្បាប់ IDEA Part C ទូទាំងរដ្ឋ។

(360) 725-3500

**www.dcyf.wa.gov**

សម្រាប់ពត៌មានពិស្តារបន្ថែម និងការបញ្ជូនទៅកាន់ បុគ្គលិកសម្របសម្រួលធនធានគ្រួសារ (FRC), សូមអញ្ជើញទូរស័ព្ទទាក់ទង Help Me Grow Washington ដើម្បីស្នើសុំឈ្មោះនៃបុគ្គលិក FRC ក្នុងមូលដ្ឋានរបស់លោកអ្នក។

1-800-322-2588

Washington State Fathers Network at Kindering Center។ គាំពារ និងផ្តល់ការឧបត្ថម្ភ និងធនធានសម្រាប់បុរសទាំងអស់ និងគ្រួសាររបស់ពួកគេ ដែលមានកូនមានតម្រូវការពិសេស។

(425) 653-4286

**www.fathersnetwork.org**

PAVE គឺជាមជ្ឈមណ្ឌលបណ្តុះបណ្តាលមាតាបិតា និងផ្តល់ពត៌មានទូទាំងរដ្ឋមួយ ដែលផ្តល់ជំនួយដល់បណ្តាគ្រួសារដែលមានកូនមានពិការភាព, ចាប់តាំងពីកំណើតរហូតដល់ពេញវ័យ។

1-800-572-7368 (800-5 PARENT)

**www.wapave.org**

Washington State Parent to Parent គឺជាបណ្តាញមាតាបិតាទូទាំងរដ្ឋមួយ ដែលផ្តល់ការគាំពារផ្លូវអារម្មណ៍ និងពត៌មានដល់បណ្តាឪពុកម្តាយ ដែលមានកូនមានពិការភាព ឬការអភិវឌ្ឍន៍កាយសម្បទាយឺតយ៉ាវ។

1-800-821-5927

**www.arcwa.org/parent-to-parent**

Arc of Washington State លើកកម្ពស់ការអប់រំ, សុខភាព, ភាពម្ចាស់ការលើខ្លួនឯង, ភាពឱបក្រសោប, និងជម្រើសនៃបុគ្គលដែលមានពិការភាពផ្នែកអភិវឌ្ឍន៍កាយសម្បទា និងគ្រួសាររបស់ពួកគេ។

1-888-754-8798

**www.arcwa.org**

The Office of Superintendent of Public Instruction មាន គេហទំព័រដែលមានប្រយោជន៍សម្រាប់គ្រួសាររបស់កុមារដែលទទួលការអប់រំពិសេស និងសេវាដែលពាក់ព័ន្ធនៅ ៖

**www.K12.wa.us/SpecialEd/Families/default.aspx**


**The Washington State Department of Children, Youth & Families Early Support for Infants and Toddlers**

PO Box 40970<br>
Olympia WA 98504-0970<br>
ទូរសារ ៖ (360) 725-4925<br>
សម្មេង ៖ (360) 725-3500<br>
**www.dcyf.wa.gov/services/child-development-supports/esit**


*ការរើសអើងត្រូវបានហាមឃាត់ក្នុងគ្រប់កម្មវិធី និងសកម្មភាពទាំងអស់។ គ្មានជនណាម្នាក់គួរត្រូវគេបដិសេធមិនយល់ព្រមឲ្យទទួលសេវាកម្មដោយផ្អែកលើមូលដ្ឋានពូជសាសន៍, ពណ៌សម្បុរ, សាសនា, គោលជំនឿ, សញ្ជាតិដើម, ភេទ, អាយុ, ឬពិការភាពឡើយ។*

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃឯកសារនេះជាទ្រង់ទ្រាយ ឬជាភាសាផ្សេងមួយ សូមទាក់ទង ផ្នែកទំនាក់ទំនងធម្មនុញ្ញ DCYF (1-800-723-4831 | 360-902-8060, **ConstRelations@dcyf.wa.gov**)។*


DCYF PUBLICATION FS_0004 CA | DEL 11-013 CA (01-2020)